**TKI0767**

# សម្ភាសន៍ជាមួយឈ្មោះ អ៊ុក ងិន ភេទប្រុស អាយុ៧១ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ មេភូមិ
## សព្វថ្ងៃរស់នៅភូមិជីរះ ឃុំព្រៃរំដេង ស្រុកគិរីវង់ ខេត្តតាកែវ
## ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ត្រី ស៊ុយហៀង

០១:០១:០៣

**៣២ទំព័រ**

ស៊ុយហៀង : ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០ ។ លោកតាជម្រាបសួរ ខ្ញុំឈ្មោះ ត្រី ស៊ុយហៀង មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាអង្គការមួយក្រៅរដ្ឋាភិបាលមួយដែលធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងទុកឯកសារប្រវត្តិសាស្ត្រ ទាក់ទងនឹងរបបខ្មែរក្រហម ។ ចឹងថ្ងៃនេះ ពួកខ្ញុំមកនឹងដើម្បីជួបសម្ភាសន៍លោកតាទាក់ទងនឹងប្រវត្តិលោកតាកាលជំនាន់នោះ លោកតាឆ្លងកាត់ម៉េចខ្លះ ហើយលោញតាមានបទពិសោធន៍ធ្វើអីខ្លះ លោកតានិយាយនូវអ៊ីដែលលោកតាបានចងចាំ ។ ចឹងខ្ញុំសុំជម្រាបសួរមុន លោកតាឈ្មោះអីគេដែរ?

ងិន : ខ្ញុំឈ្មោះនេះ អ៊ុក ងិន ។

ស៊ុយហៀង : លោកតាអាយុប៉ុន្មាន?

ងិន : ៧១ហើយ ។

ស៊ុយហៀង : លោកតាស្នាក់នៅណាដែររាល់ថ្ងៃ?

ងិន : ស្នាក់នៅជាមួយកូន នៅនឹងដែរ ។

ស៊ុយហៀង : នៅនឹងភូមិអីដែរ?

ងិន : ភូមិជីរះ ឃុំព្រៃរំដេង ។

ស៊ុយហៀង : ស្រុក?

ងិន : គិរីវង់ ។

ស៊ុយហៀង : ខេត្តតាកែវ?

ងិន : ហ្នឹង ។

ស៊ុយហៀង : ចឹងលោកតាសុំសួរតាំងពីដើម លោកតាកាលនឹងមានរៀនមានសូត្រទេ ពីដើម?

និន ៖ កាលជំនាន់នឹង មានរៀនមានសូត្រចឹងដែរ តែការងាររៀនសូត្រ ការងារប្រជុំរៀន ដូចតែគ្នា កូនចៅក៏មានរៀននឹងសាលា ប៉ុនសាលាវាមិនទៀង ជួបកាលក្រោមផ្ទះ ជួនកាលម្លប់ឈើអីចឹងទៅ ។

ស៊ុយហៀង ៖ ចុះមុននឹង លោកតាមានរៀនមានអីទេ កាលនៅក្មេង?

និន ៖ កាលនៅក្មេងមានរៀនដែរ រៀនសាលាវត្ត ។

ស៊ុយហៀង ៖ វត្តណាដែរ?

និន ៖ វត្តអង្គរុន ។

ស៊ុយហៀង ៖ លោករៀនដល់ថ្នាក់ទីប៉ុន្មាន?

និន ៖ ហ៉ា! រកថ្នាក់មិនឃើញ ប្រហែលជាថ្នាក់ទី១០ទីអីនឹង ។

ស៊ុយហៀង ៖ ចេះអាន ចេះសរសេរដែរ?

និន ៖ សរសេរដែរ ប៉ុនវាមិនសូវបានស្ទាត់ជំនាញ ។

ស៊ុយហៀង ៖ ចុះដល់ពេលជំនាន់លន់ នល់ លោកតាធ្វើអីដែរ?

និន ៖ ជំនាន់ លន់ នល់ ជាប់ប្រធានក្រុមដែរ ។

ស៊ុយហៀង ៖ ធ្វើអីដែរ?

និន ៖ ទេ! គ្មាន ។

ស៊ុយហៀង ៖ អត់មានធ្វើអី តែជាប់ឈ្មោះ?

និន ៖ អានេះគ្រាន់ជាប់តែឈ្មោះ គ្មានគៀងគរប្រជាជន ។

ស៊ុយហៀង ៖ ពីណាគេចាត់តាំងឲ្យអ៊ំធ្វើប្រធានក្រុម?

និន ៖ អានឹងថ្នាក់ឃុំ ថ្នាក់ភូមិគេ ។

ស៊ុយហៀង ៖ គណៈឃុំ?

និន ៖ អឺ!

ស៊ុយហៀង ៖ គណៈឃុំនឹងអ្នកណា?

និន ៖ ឃុំជំនាន់នឹង ឈ្មោះតាដាន ស្លាប់ ។

ស៊ុយហៀង ៖ ឈ្មោះតាដាន ស្លាប់បាត់ហើយ ។ លោកតានៅក្រុមអីគេ?

និន ៖ ក្រុម?

ស៊ុយហៀង ៖ លោកតាមិញថាធ្វើមេក្រុម?

ងិន ៖ ហ៎! ក្រុមនោះមិននាមថាក្រុមទី១ ទី២អីទេ គ្រាន់តែគេថាជាប់នាមចាត់តាំងឲ្យធ្វើក្រុមតែប៉ុន ។

ស៊ុយហៀង ៖ ធ្វើក្រុមនឹងធ្វើខាងអីដែរ?

ងិន ៖ ក្រុមប្រជាជនភូមិ ។

ស៊ុយហៀង ៖ ហើយលោកតាមើលការខាងអី?

ងិន ៖ ជំនាន់នោះ គ្រាន់តែថាៗហើយចោលទេ អត់មានទៅគ្រប់គ្រងស្អីទេ ។

ស៊ុយហៀង ៖ អូ! អត់មានធ្វើស្អីទាំងអស់ មានតែឈ្មោះ?

ងិន ៖ ហ្នឹងហើយ មានតែឈ្មោះ ។

ស៊ុយហៀង ៖ ចុះអំឡុងពេលប៉ុន្មានឆ្នាំ នៃរបបលន់ នល់នោះលោកនៅតែធ្វើចឹងរហូត?

ងិន ៖ ទល់តែរំដោះខ្មែរក្រហមចូលដល់ បានថយ ។

ស៊ុយហៀង ៖ ឆ្នាំណាដែរ?

ងិន ៖ ៧០ ៗ នឹងលន់ នល់ ត្រូវថយហើយ ។

ស៊ុយហៀង ៖ លោកតាធ្វើអីទៀត?

ងិន ៖ ដល់ថយពីនឹងមក មាននៅតែស្រែធ្វើស្រែវិញ ។

ស៊ុយហៀង ៖ លោកតាមានចូលបដិវត្ត ចូលអីដែរ?

ងិន ៖ គ្មាន ។

ស៊ុយហៀង ៖ អត់មានចូលទេ?

ងិន ៖ គ្មាន អត់មានចូលទៅណា នៅតែផ្ទះ នឹងម៉ង ។ ដល់គេមកគេចាត់តាំងឲ្យធ្វើក្រុមធ្វើអីបន្តទៀត អានឹងបម្រើជាមួយប្រជាជនចឹងទេ ។ មិនចឹងទេ ក្រុមចេញចោលផ្ទះសម្បែង នាយទុននៅព្រៃដែរអត់ទេ ។

ស៊ុយហៀង ៖ អំនៅធ្វើចឹងរហូតដល់ខ្មែរក្រហមចូលមក?

ងិន ៖ ហ្នឹងហើយ ។

ស៊ុយហៀង ៖ ដល់ពេលខ្មែរក្រហមចូលមក គេចាត់ឲ្យលោកតាធ្វើអី?

ងិន ៖ ធ្វើក្រុមទៀត ។

ស៊ុយហៀង ៖ ក្រុមភូមិនឹងម៉ង?

ងិន ៖ ហ្នឹងហើយក្រុមនៅក្នុងភូមិ ។ រួចមកបានមកដល់៧៦ ៧៧បានធ្វើមេភូមិកាលប៉ុលពត វាឆ្លងកាត់៧៥ចូល៦ ៧ នោះ បាន៤ឆ្នាំ យើងត្រូវរំដោះក្រោយនោះ ។

ជាតិ : ឆ្នាំណាអ៊ំគេឲ្យអ៊ំធ្វើឈ្លប?

និន : អាឈ្លបនឹង តាំងពីមិនទាន់មេឃុំ អានោះមិនទៅជាមួយទ័ពនោះ ទ័ពគេចូលមុនដំបូង ទ័ពគេចូលដល់ៗ មិន៧២ទ័ពគេចូលមករំដោះបាននៅកន្លែងនេះ កាលខ្មែរក្រហមនឹងៗ ដល់រួចពីនឹងមកនៅជាមួយទ័ពនឹង មេឃុំគេមកគេចាត់តាំងថ្មី ទាល់តែឆ្នាំ៧៦ ៧៧នឹង បានគេចាត់តាំងធ្វើភូមិៗ

ជាតិ : ចុះពេលគេចូលមកឆ្នាំ៧២នឹង មេភូមិចាស់គេយកទៅណា?

និន : មេភូមិចាស់នៅចឹងដែរ ឃើញថាវាសុខរហូតៗ

ជាតិ : អត់អី អត់ផ្លាស់ប្តូរអី?

និន : អត់ទេៗ

ជាតិ : ចុះឃុំវិញ?

និន : ឃុំគាត់ទៅបាត់រហូតៗ

ជាតិ : ហើយអ្នកថ្មីគេចូលមក?

និន : ពី៧៣ អាមេឃុំប៉ុលពត គេចូលមក តែមេឃុំយើងនៅមូលដ្ឋាននេះទៅបាត់ហើយ បាត់រហូតៗ

ជាតិ : គេចាត់ ឬមួយគាត់រត់?

និន : គាត់រត់ៗទៅបាត់រហូត មិនឃើញវិលៗ

ជាតិ : ហើយអ៊ំធ្វើឈ្លបនឹង ធ្វើឈ្លបឲ្យខាងណា?

និន : ខាងខ្មែរក្រហមនឹងៗ

ជាតិ : ប្រធានភូមិឈ្មោះអីកាលនឹង?

និន : ប្រធានភូមិកាលនោះឈ្មោះ តប់ ស្លាប់បាត់ៗ

ជាតិ : តាតប់ត្រូវជាសាច់ញាតិអ៊ំ?

និន : មិនទេ ត្រូវជាញាតិភូមិៗ

ជាតិ : ប៉ុន្មាននាក់ធ្វើឈ្លបជំនាន់អ៊ំ ពួកម៉ាក់អ៊ំ?

និន : វាអានឹងទៅបាត់អស់ដែរ ហើយរកថាប៉ុន្មាននាក់ វាមានច្រើនដែរៗ

ជាតិ : ច្រើន?

និន : ប៉ុនគេបាត់អស់ ប៉ុនបាត់ងាប់ទេ មិនមែនបាត់រស់ៗ

ជាតិ : អ៊ំស្ម័គ្រចិត្តចូល ឬមួយគេ?

ងិន : មិនទេ មកគេចេះហៅប្រើៗទៅធ្វើ ពេលគេមើលឃើញចាត់តាំងក្រៅ ខ្ទាំងបោះឆ្នោត គ្មានស្អីអានឹង ។

ជាតិ : ចូលឈ្លបនឹងឆ្នាំ៧២?

ងិន : បាទ!

ជាតិ : ចូលឈ្លបភ្លាមគេឲ្យអ៊ំធ្វើអីខ្លះ ទៅរាយការណ៍ដល់ណា?

ងិន : ទេ! គ្មានទៅអី នៅផ្ទះ បើតាមគិតធ្វើៗដើម្បីស្រែភ្លឺតែម្ដង គ្មានហៅទៅសួរស្អីណាទៅបំពាក់បំប៉ននឯណា ។

ជាតិ : អត់ទេ?

ងិន : អត់ ។

ជាតិ : តែតួនាទីធ្វើស្អីដែរ ឈ្លប?

ងិន : តួនាទីរបស់វា បើតាមមើលវាថាឲ្យដើរមើលប្រជាជន អ្នកណាធ្វើម៉េចៗរាយការណ៍ តែវាគ្មានស្អីទេ ប្រាប់តែប្រជាជនថា តែគេប្រើឲ្យធ្វើស្អីធ្វើនឹងទៅ ស្រែភ្លឺយើងដឹងស្រែភ្លឺ មិនចាំបាច់គិតស្អីច្រើន ។ ប៉ុនថាឃើញថាចឹងទៅវាសុខរហូត តែប៉ុននឹងទៅដល់ភូមិគេក្រោយៗ ទៅលើគេ...វានៅលើភូមិគេហើយ ។ ដល់គេចាត់តាំងទៅភូមិគេនឹងទៅ នៅនឹងភូមិនឹង ដល់មក៧៦ ៧៧នឹង វាបាត់ ។

ជាតិ : ហើយអ៊ំកាន់កាំភ្លើងប៉ុន្មានដើម កាលគេឲ្យធ្វើឈ្លបដំបូង?

ងិន : កាំភ្លើងគ្មាន ។

ជាតិ : អត់មានទេ?

ងិន : អត់ ហើយរួមផ្សំនឹងប្រជាជន មិនចាត់តាំងនឹងចេញឈ្លបភូមិ ចេញឈ្លបឃុំ គ្រាន់ថាជំនួសៗដៃ មាត់ ពាក្យអីអាតិចតួចទៅ វាមិនបានដល់ទៅគ្រឿងអាវុធទេ ។

ជាតិ : អ៊ំមានដែលទៅប្រជុំ ទៅអី?

ងិន : ប្រជុំដែរ មិនអត់ទេ ។

ជាតិ : ប្រជុំណាខ្លះដែរ កាលជំនាន់ធ្វើឈ្លប?

ងិន : ទៅប្រជុំវានៅខាងត្រពាំងរុន គេហៅវត្តមង្គលៗ ។

ជាតិ : កន្លែងអីគេ ត្រពាំងរុន?

ងិន : កន្លែងស្រុក ។

ជាតិ : ការិយាល័យស្រុក?

ងិន : ហ្នឹង ។

ជាតិ : ស្រុកប៉ុន្មាន?

ងិន : ស្រុក១០៩ ។

ជាតិ : ១០៩នៅត្រពាំងរុនម៉ង់?

ងិន : ហ្នឹងហើយ ។

ជាតិ : ត្រពាំងរុននៅណាវិញ?

ងិន : ត្រពាំងរុន ដើង ។

ជាតិ : ការិយាល័យស្រុកនៅក្នុង អ៊ំស្គាល់កន្លែងទីតាំងរាល់ថ្ងៃ ភូមិអី?

ងិន : ភូមិត្រពាំងរុននឹងម៉ង់ ។

ជាតិ : ភូមិត្រពាំងរុន ឃុំត្រពាំងរុន?

ងិន : មិនឃុំទេ ឃុំរាមអណ្តើត ។

ជាតិ : អ៊ំប្រជុំជាមួយអ្នកណាគេ កាលនឹង?

ងិន : ហ៎! មិនស្គាល់គេដែរ គេហៅទៅៗ មិនដឹងជាអ្នកណាជាអ្នកណែ ។

ជាតិ : ទៅច្រើនទេ?

ងិន : វាច្រើនដែរ ម៉ាឃុំ ជួនគេហៅម៉ាស្រុក បើតាមជាស្គាល់ វាគ្មានស្គាល់គ្នាទេ ។

ជាតិ : អ៊ំស្គាល់គណៈស្រុកទេ ជំនាន់នឹង?

ងិន : ស្រុកកាលនឹងវា មិនដែលចូលរួមបានជាមួយស្រុកនឹង ឲ្យច្បាស់លាស់អីទេ ។

ជាតិ : តែត្រូឈ្មោះទេ?

ងិន : ឈ្មោះ មិនដឹងណាធំ អ្នកណាតូចផង ។

ជាតិ : តែពីណាខ្លះឈ្មោះ?

ងិន : មានឈ្មោះយាយយឿន យាយបូ ភូមិភាគ ។

ជាតិ : យាយបូ ហើយពីណាគេទៀត អ៊ំធ្លាប់ត្រូឈ្មោះ អ្នកណាគេខ្លះទៀត?

ងិន : វាគ្រាន់តែត្រូឈ្មោះនឹង មានតែតាម៉ុកនឹង យាយយឿននឹង យាយបូនឹង តែ៣នាក់ ៤នាក់ ។ អាកូនចៅដឹងអ្នកណាខ្លះទេ អត់យល់ ។

ជាតិ : ពេលប្រជុំគេនិយាយពីស្អី ពេលប្រជុំ?

ងិន : ទេ! មិនចាំ និយាយពីបង្កបង្កើនផលដូចយើងរាល់ថ្ងៃនឹងចឹងដែរ ។ អារឿងក្រៅវាគ្មាន ពេលនិយាយប្រជុំមិនខុសប្លែកពីឥឡូវ ។

ជាតិ : ឥឡូវនឹងបង្កបង្កើនផល ជួយលើកទំនប់ ធ្វើស្រែចឹងទៅ?

ងិន : ទៅប្រឡាយនិយាយប្រឡាយ ត្រូវថ្នល់ៗចឹងទៅធ្វើស្រែថាធ្វើស្រែចឹងទៅ ។

ជាតិ : អត់ទេអានេះ និយាយពីរឿងអ៊ំប្រជុំកាលដែលអ៊ំធ្វើឈ្លប អត់ទាន់ដល់ប្រជុំក្រោយៗ?

ងិន : អាឈ្លបនឹងគ្មានទេ ។

ជាតិ : អត់សូវ?

ងិន : អត់ មិនត្រូវការត្រង់ឈ្លបភូមិគ្មាន គេអត់ហៅចូលរួមទេ ។

ជាតិ : ចឹងមានការផ្លាស់ប្តូរប្រធានភូមិអីទេ រហូតដល់ឆ្នាំ៧៥ បែក?

ងិន : តាំងពីបង្កើតមេឃុំនឹងមក បង្កើតមេភូមិនឹងមក គេបង្កើតឈ្លបគេ យើងគេឲ្យនៅជាមួយប្រជាជនវិញ ។

ជាតិ : ឈ្លបឃុំវិញ?

ងិន : អាឈ្លបឃុំនឹងហើយ មិនមែនឈ្លបដើរយកការណ៍នោះទេ អាមួយឈ្លបភូមិ មួយឈ្លបឃុំ ដល់គេបានឈ្លបឃុំគេមក មេឃុំគេមកចាត់តាំងនៅកន្លែងនេះ យើងភូមិនៅស្ងៀមហើយ ។ គេកាន់កាប់គ្នាគេ ឈ្លបឃុំនេះហើយ យើងដឹងថយមកខាងស្រែភ្ជួរនេះវិញ ។

ជាតិ : ស្រែភ្ជួរវិញ?

ងិន : ហ្នឹងហើយ ។

ជាតិ : ចឹងអ៊ំអាចរៀនបរាប់បានទេ អាឆ្នាំបែកភ្នំពេញឆ្នាំ៧៥ យ៉ាងម៉េចដែរ ហេតុការណ៍យ៉ាងម៉េច? ១៧/មេសាឆ្នាំ៧៥?

ងិន : វាយ៉ាងម៉េចវិញ?

ជាតិ : បែកភ្នំពេញកាលនឹង ។

ងិន : បែកភ្នំពេញវាមានស្អី អត់មានស្អី ។

ជាតិ : មានប្រជាជនថ្មីគេជម្លៀសមកទេ?

ងិន : មានៗ ៧៥ឃើញតែគេមក មានឡាន មានម៉ូតូគេមក នៅវត្តអង្គរុននឹង វាមានបាត់វាមានហើយ មិនដឹងថាមានបាត់នឹងរបៀបម៉េច មិនដឹងដែរ(សើច) ។

ជាតិ : មកច្រើន?

ងិន : មកច្រើនខ្លះ ក៏បាត់ទៅវិញទៅខ្លះៗ នៅទល់រហូតឥឡូវនឹងដែរ ។

ជាតិ ៖ ភាគច្រើនគេមកពីណា?

ងិន ៖ ភាគច្រើនគេមកបែកពីភ្នំពេញមក ។ ស្រុកកំណើតមកវាបែករហូត មកមានអីទៅសប្បាយរហូត បើមានគ្រោះថ្នាក់ មានតែគេឆ្ងាយៗទៅវិញ រកគ្រោះថ្នាក់ខ្វះដែរ មិនមែនតែគេទេ តែក្នុងភូមិអត់មានខូចខាត ។

ជាតិ ៖ ចុះពីណាគេ ប្រធានភូមិមុនអ៊ំ?

ងិន ៖ ឈ្មោះ តប់ ។

ជាតិ ៖ គាត់ស្លាប់ឆ្នាំណា?

ងិន ៖ គាត់ស្លាប់តាំងពី៧៧ ។

ជាតិ ៖ តែអ៊ំឡើងៗឆ្នាំ៧៦?

ងិន ៖ បាទ!

ជាតិ ៖ ចឹងពេលអ៊ំឡើង គាត់អត់ទាន់ស្លាប់ទេ?

ងិន ៖ ពេលខ្ញុំឡើងនឹង វាថាជាប់ទោសដោយសារនារី ។

ជាតិ ៖ ដោយសារអី?

ងិន ៖ ដោយសារនារី ។

ជាតិ ៖ នារី?

ងិន ៖ អឺ! ដល់គេផុតទៅ បានខ្ញុំទទួលពាក្យនឹងឡើង វាខូចនារី ។

ជាតិ ៖ នារីៗនឹងនៅណា?

ងិន ៖ នារីនឹងក៏បាត់ដែរ ។

ជាតិ ៖ ហើយនារីនឹងនៅភូមិនឹង ឬមួយក៏?

ងិន ៖ ភូមិនឹងប៉ុនស្លាប់ដែរបាត់ ។

ជាតិ ៖ គេជាប់ទោសនឹង គេចាប់គាត់យកទៅណា?

ងិន ៖ ចាប់យកទៅរៀនសូត្រ ដឹងយកទៅត្រង់ណាមកណា តែចាប់បាត់ហើយ មិនថាមេភូមិមេឃុំ ជំនាន់នោះ ។

ជាតិ ៖ ចុះប្រពន្ធកូនគាត់ម៉េចទៅ?

ងិន ៖ ប្រពន្ធកូនគាត់មានអី តែស្ងាត់ ទៅដល់តែចឹងហើយគ្មានអ្នកណាដឹងថាគវ៉ាម៉េចគ្មានតែបាត់ៗ ។

ជាតិ ៖ ហើយគេតំឡើងអ៊ំធ្វើមេភូមិទៅ?

និន ៖ ហ្អឹង ។

ជាតិ ៖ អ្នកណាគេអ្នកតែងតាំង អ៊ំជាមេភូមិ?

និន ៖ មេឃុំគេ ។

ជាតិ ៖ មេឃុំឈ្មោះអី?

និន ៖ មេឃុំគេឈ្មោះ មកចាប់មេភូមិនឹង ខាងរាមអណ្ដើតឈ្មោះ ឆន ។

ជាតិ ៖ អ្នកចាប់មេភូមិឈ្មោះ ឆន?

និន ៖ អាចាត់មេភូមិនឹង?

ជាតិ ៖ បាទ!

និន ៖ អឺ! អានឹងមិនដឹងពីខាងណាគេមកទេ មានតែមេឃុំគេនៅនឹង តាអឿន តាអី តាំងពីនៅព្រៃរំដេងនោះ រួចទៅបានខ្ញុំផ្លាស់ទៅនៅរាមអណ្ដើក ហើយដល់វគ្គតាមេភូមិនឹងផ្លាស់ប្ដូរភូមិហើយ គេខាងនេះទៅនៅ....(ស្ដាប់មិនបាន) ខ្ញុំទៅនៅរាមអណ្ដើកទៅ ។

ជាតិ ៖ ប៉ុន្ដែអ្នកតែងតាំងអ៊ំនឹង មេឃុំ?

និន ៖ មេឃុំ ។

ជាតិ ៖ គេតែងតាំងអ៊ំនឹង គេមានវិធីមានអីរៀបចំ?

និន ៖ គ្មាន ។

ជាតិ ៖ គេថាម៉េចទៅ គេមកនិយាយថាម៉េច?

និន ៖ ទេ! ថាឲ្យដឹកនាំប្រជាជនធ្វើការទៅ ។

ស៊ុយហៀង ៖ គេមកផ្ទះអ៊ំ ឬគេមកហៅអ៊ំ?

និន ៖ គេមិនមានកន្លែងឃុំដូចឥឡូវទេ គេនៅផ្ទះប្រជាជនជំនាន់នោះ គេមិនសង់ផ្ទះមេឃុំមេស្រុកគេណា ទាល់តែកន្លែងស្រុកគេ គេមានកន្លែងទំពាឈ្ងបគេការពារ អានឹងទៅអានឹងបានមាន តែឃុំស្នាក់នៅជាមួយភូមិ ជាមួយប្រជាជននឹងទេ ។

ស៊ុយហៀង ៖ គេហៅលោកតាទៅជាជួប ឬមួយក៏គេមកជួយលោកតា?

និន ៖ គេនៅជាមួយតែគ្នានឹង ដើរទៅមកៗ ហើយគេចូលលេងទៅ ។

ស៊ុយហៀង ៖ ពេលគេតែងតាំងលោកតា?

និន ៖ អត់ទេ គេប្រជុំអីពីស្រែភ្ជួរឹងទៅ គេប្រាប់ប្រជាជនទៅ ថាឯងគ្រប់គ្រងភូមិនឹងទៅនាំប្រជាជនធ្វើស្រែចំការចឹងទៅ អានឹងគ្រាន់តែប៉ុននឹងទេ ។

ជាតិ ៖ មេឃុំនឹងឈ្មោះអីលោកតា?

ឌិន ៖ មេឃុំនឹង តាំងពីមេឃុំឈ្មោះ ឆន គ្មាននៅមួយទេ ។

ស៊ុយហៀង ៖ ទៅបាត់ខ្លួន ឬស្លាប់?

ឌិន ៖ មិនដឹង។ទៅរកស៊ីស្អី ហើយក៏ទៅស្លាប់ ហើយក៏ទៅម៉េច ម៉ារត់៧៩ វាបាត់រហូតទៅ ។

ស៊ុយហៀង ៖ ត្រឡប់មកកន្លែងលោកតាធ្វើមេភូមិនឹង លោកតាធ្វើរហូតដល់ឆ្នាំ៧៩មក?

ឌិន ៖ ខ្ញុំចាប់ពី៨៤ ។

ស៊ុយហៀង ៖ អត់ទេ មេឃុំខ្មែរក្រហម?

ឌិន ៖ អូ! ខ្មែរក្រហមមិនទេ ទើបនឹង៧៦ ។

ស៊ុយហៀង ៖ រហូតដល់អន្កាល់?

ឌិន ៖ រហូតដល់៧៩ ចប់ម៉ង ។

ស៊ុយហៀង ៖ ចឹងអំឡុងពេលនឹង លោកតាមានឃើញការចាប់ខ្លួនប្រជាជនអ្នកភូមិលោកតាទេ?

ឌិន ៖ គ្មានទេ ក្នុងភូមិគ្មាន ។

ស៊ុយហៀង ៖ អត់មានគេចាប់?

ឌិន ៖ អត់ ។

ស៊ុយហៀង ៖ ចឹងលោកតាអត់មានឃើញគេចាប់ពីភូមិនេះ យកទៅដាក់គុកនេះ អត់មាន?

ឌិន ៖ កន្លែងគុក គេមានឃ្លាតណាស់ ។

ជាតិ ៖ នៅណាវិញ?

ឌិន ៖ ឯលិចវត្ត ។

ស៊ុយហៀង ៖ វត្តអីគេ?

ឌិន ៖ ខាងលិចវត្តអន្គរុន ។

ស៊ុយហៀង ៖ វត្តអន្គរុន មានគុកដែរ?

ឌិន ៖ ទេ! អានឹងនៅផ្ទះប្រជាជន អានឹងដូចជាគុកដែរ ។

ស៊ុយហៀង ៖ ចឹងគេចាប់ដាក់នឹងដែរ?

ឌិន ៖ ចាប់ដាក់ផ្ទះ ។

ស៊ុយហៀង ៖ មានច្រវ៉ាក់ មានអីដាក់ដែរ?

ឌិន ៖ អាខាងនឹងគេមានខ្នោះឈើខ្នោះអី ប៉ុនមិនដែលឃើញផង ឮថាមានឃ្នោះ ។

ស៊ុយហៀង ៖ កាលនឹងលោកតាពុទឹង ពុពីឆ្នាំ៧៦នឹងម៉ង ឬមួយទើបនឹងពុឥឡូវ ពុពីជំនាន់អាពត
នឹង ឬមួយក៏ពុឥឡូវ?

ងិន ៖ ពុតាំងពីនឹងមក ។

ស៊ុយហៀង ៖ អាពតនឹង?

ងិន ៖ អឺ! ពុតាំងពីនឹងមកហើយ ។

ស៊ុយហៀង ៖ ពីណាគេអ្នកប្រាប់លោកតាៗដែលទៅមើល?

ងិន ៖ មិនដែលទៅមើលផង ។

ស៊ុយហៀង ៖ ប៉ុន្តែពីណាគេអ្នកប្រាប់លោកតា ថាមាន?

ងិន ៖ មាត់មនុស្សនិយាយ ។

ស៊ុយហៀង ៖ ពីណាអ្នកនិយាយ?

ងិន ៖ ហេ៎! ពីណាអ្នកនិយាយទៀត គ្មានៗដឹងអ្នកនិយាយទេ អត់មានបៀមទុក អត់ ។

ស៊ុយហៀង ៖ ចឹងពេលលោកតាដឹងថានៅនឹង នៅជិតវត្តអង្គរុនមួយដែរ?

ងិន ៖ ពុថាមាន ព្រោះកន្លែងនឹងឈ្លបកន្លែងស្រុកគេ ។

ស៊ុយហៀង ៖ ភាគច្រើនគេចាប់ពីណាយកទៅដាក់នៅនឹង?

ងិន ៖ មិនដឹងពីណាខ្លះទេ ។

ស៊ុយហៀង ៖ លោកតាអត់ដែលទៅមើលសោះ?

ងិន ៖ មិនគួរដល់គេមានកន្លែងគេនោះ ខ្ញុំនេះទៅហើយមិនងាយបានមកនេះទេ ។

ស៊ុយហៀង ៖ ទៅណាលោកតា?

ងិន ៖ គេផ្លាស់កន្លែង ផ្លាស់ភូមិ ។

ស៊ុយហៀង ៖ លោកតាទៅណាវិញ?

ងិន ៖ ភូមិហ្នឹង ក៏អត់បាននៅនឹងដែរ គេឲ្យទៅនៅនោះចឹងទៅណា កន្លងវាលទៅនៅខាង
ភូមិត្បូងវត្តតាមផ្លូវនេះ ។

ជាតិ ៖ ក្នុងភូមិអឹម៉ង ប្រជាជនដំបូងមានប៉ុន្មាននាក់ កាលឆ្នាំ៧៦នឹងមានប៉ុន្មាននាក់?

ងិន ៖ ដំបូងទាំងអស់ប្រហែលត្រឹម៣០-៤០គ្រួសារ ។

ជាតិ ៖ ប្រជាជនថ្មីប៉ុន្មានគ្រួសារមកពីជម្លៀស?

ងិន ៖ ប្រជាជនថ្មីនឹងប្រហែលជាជាង១០ប៉ុននឹង ។

ជាតិ ៖ ហើយអ៊ំជាប្រធានភូមិ មានរបបអីខ្លះដែរ មានរបបដូចម៉្តូ កង់?

ងិន ៖ គ្មានៗ ។

ជាតិ ៖ ចុះមេឃុំមានទេ?

ងិន ៖ មេឃុំគេមានត្រឹមកង ។

ជាតិ ៖ អត់មានរបបម៉ូតូ?

ងិន ៖ គ្មានទេ ។

ជាតិ ៖ ចុះអ៊ឹំអត់មានរបបកង់?

ងិន ៖ មានអាកង់យើងទិញម៉ង់ រឿងរបបគ្មានៗ របបគេឲ្យអត់ ។

ជាតិ ៖ អ៊ឹំជាមេភូមិ ពេលឆ្នាំ គេជម្លៀសគេដកទ្រព្យសម្បត្តិប្រជាជនមក គេយកទុកកន្លែងណា?

ងិន ៖ អានឹងគេ បើគាត់គិតកន្លែងនឹងគ្មានដក ។

ជាតិ ៖ អត់ដក?

ងិន ៖ អត់ ។

ជាតិ ៖ ប្រជាជនមានអីមានទៅ?

ងិន ៖ បើប្រជាជននៅក្នុងភូមិនឹង គ្មានដក ។

ជាតិ ៖ ចុះប្រជាជនថ្មីមាន?

ងិន ៖ ថ្មីមកគ្មានស្អី មានខោអាវម៉ាកញូបម្នាក់ ។

ជាតិ ៖ ចុះថាដាក់រួមនោះ?

ងិន ៖ ដាក់រួមអានេះគេនិយាយចេះទេ រឿងដាក់រួមនឹងតែគោក្របីស្រែភ្លឺ ។

ស៊ុយហៀង ៖ ចុះផ្ទះនោះ?

ងិន ៖ ផ្ទះនៅកន្លែង ខ្ញុំនៅយ៉ាងនឹង នៅដូចធម្មតានឹងផ្ទះ តែស្រែភ្លឺដាក់រួមនឹង ដើម្បីគេប្រមូលមកគេធ្វើជាសហករណ៍យើងធ្វើទាំងអស់គ្នាចឹងទៅ ឡើងមកវិញ ហូបបាយហូបទាំងអស់គ្នា អានឹងមាន ។ ហើយវាគ្មានប្លែកពីណាទៀត អត់ទេ ។ ចឹងគេដាក់រួមនឹងដើម្បីគេស្រណុក ចាត់តាំងឲ្យទៅធ្វើស្អីមួយ ដូចថាឲ្យទៅធ្វើស្រែ ឲ្យទៅធ្វើប្រឡាយ អានឹងវាស្រណុកដកកម្លាំងទៅចំការឆ្ងាយ វាស្រណុកចែកកម្លាំងនឹង ។ ហើយបើយើងទៅនៅតាមផ្ទះ អានឹងដកធ្វើមិនកើតទេ ។

ជាតិ ៖ ហើយអ៊ឹំ ចុះពូណាគេចាត់ចែងឲ្យថាពូនេះទៅភ្ជួរ ពូនេះគាត់ទៅដក អ្នកណាគេចាត់ចែង?

និន : អានឹងទៅដល់មេឃុំគេ គេប្រើ គេប្រាប់ថា ឥឡូវសុំ៣-៤-៥នាក់ យើងប្រជុំគ្នាដកទៅ គេស្រូតទៅប្រឡាយទៅៗ នេះទៅធ្វើស្រែប្រាំងទៅៗ នេះទៅចំការទៅៗ ប៉ុននឹង ។

ជាតិ : ចឹងខាងឃុំគេរាយការណ៍មកពូ?

និន : ហ្នឹងហើយ ។

ជាតិ : ដើម្បីដកប្រជាជននៅនេះប៉ុន្មាននាក់ ពូប្រជុំរួចបញ្ជូនទៅ?

និន : ហ្នឹងហើយ ។ បញ្ជូនទៅមកវិញដេកផ្ទះ ប៉ុនទៅធ្វើម៉ាពេលៗ វាមិនទៅចោលផ្ទះរាប់ខែរាប់ឆ្នាំ ។

ស៊ុយហៀង : គាត់ធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ភាគច្រើន?

និន : ធម្មតា ។

ស៊ុយហៀង : ចុះហូបចុកម៉េចដែរ?

និន : ហូបចុក យើងមុនដំបូង យើងហូបបាយតាមផ្ទះដែរនឹង ។

ជាតិ : បាទ! ដំបូងតាមផ្ទះក្រោយមកបានរួមធំ ។

និន : បាទ! ដល់មករួម៧៥នឹង រួមបាន២ឆ្នាំដែរ ឆ្នាំងធំនឹង ។ ប៉ុនដល់មកឆ្នាំងធំ វាមិនអត់មិនឃ្លាន ធម្មតា ។

ជាតិ : ចុះអ្នកណាគេកាន់ចុងភៅ ឃុំអុំ?

និន : កាន់ចុងភៅស្លាប់អស់ទៅហើយ ។

ជាតិ : គាត់ឈ្មោះអី?

និន : ឈ្មោះ ហ៊ុន ។

ជាតិ : គាត់ត្រូវជាអីនឹងអ៊ុំកាន់ចុងភៅ?

និន : គ្មានធ្វើស្អី ធ្វើប្រជាជន ។

ជាតិ : ចុះគ្រួសារអ៊ុំ ឲ្យគេធ្វើអី?

និន : គ្រួសារខ្ញុំក៏ស្រែភ្លឺនឹងគេ ដូចតែគ្នា ។

ជាតិ : អត់កាន់ចុងភៅទេ?

និន : អត់ទេ ។

ជាតិ : ហើយអ៊ឹកងសេដ្ឋកិច្ចដូចថាព្រលឹមឡើង ត្រូវតែចេញទៅធ្វើដកព្រលិត ចាប់ត្រីចាប់អី អ៊ុំចាត់ចែង ឬមួយខាងណាចាត់ចែង?

និន ៖ អានឹងខ្ញុំចាត់ចែង អារឿងអ្នករកម្ហូបរកបន្លែៗ រឿងអ្នកចំអិន ។

ជាតិ ៖ អ៊ំអាចចាត់តាំងបានដែរ?

និន ៖ បាន ហឺ! មិនបាននៅក្នុងភូមិនឹង បើចាត់តាំងមិនបានៗ អីហូប ។

ជាតិ ៖ ហើយចុះពេលបានស្រូវមកគេយកទុកកន្លែងណា ខែប្រូតនឹង?

និន ៖ ស្រូវខែប្រូតកាត់វាបានមកដាក់នៅក្នុងភូមិដែរនឹង ។

ជាតិ ៖ ដាក់នៅក្នុងសហករណ៍ភូមិ?

និន ៖ ហ្នឹងហើយ ។

ជាតិ ៖ ហើយក្រោយមក ពីណាគេមកយកស្រូវនឹង?

និន ៖ ទេ! បើតាមស្រូវក្នុងភូមិនេះ គ្មានៗអ្នកណាយកទៅណា ។

ជាតិ ៖ អត់អ្នកណាយកទៅណា?

និន ៖ បាទ!

ជាតិ ៖ ចែកអ្នកភូមិទាំងអស់?

និន ៖ នៅគ្រប់គ្រងនៅនឹង ជាមួយ មុនដំបូងចែកឲ្យហូប អស់ពីចែកឲ្យហូបឆ្នាំងរួមអានឹងក៏នៅក្នុងនឹង អត់មានដឹក ។

ជាតិ ៖ តែស្រូវសល់អត់មានដឹកទៅលើ?

និន ៖ អត់បានសល់ បានម៉ាគ្រប់ ។

ជាតិ ៖ ម៉េចចឹងអត់សល់ បក្សអត់រករឿង ឃុំអត់ររករឿង?

និន ៖ ទេ! ឃុំវាចេញចូលនឹងដែរ ដឹងស្រូវអស់មិនអស់ ។

ជាតិ ៖ ចុះភូមិផ្សេងៗទៀត មានសល់ស្រូវ?

និន ៖ មានសល់ មានខ្វះ ។

ជាតិ ៖ មានខ្វះដែរ?

និន ៖ ហ្នឹងហើយ បានថាវាសល់វាខ្វះ កន្លែងនេះវាមានសល់មានខ្វះ វាមិនបានដល់អាខ្វះដាច់ពេល វាខ្វះត្រឹមល្មមដោះស្រាយរួច ។

ជាតិ ៖ ចឹងអត់មានដឹកទៅកាន់សហករណ៍ភូមិ-ឃុំ?

និន ៖ មិនបានដឹកចេញ នៅកន្លែង ។

ជាតិ ៖ ហើយអ៊ំថាមិញ ២អាទិត្យ ម៉ាខែ២ដងត្រូវជួបប្រជុំមេឃុំ?

និន ៖ អានឹងមេឃុំយើងឥឡូវរាល់ថ្ងៃនេះ ។

ជាតិ ៖ រាល់ថ្ងៃនេះទេ មិនមែនជំនាន់ខ្មែរក្រហម?

និន ៖ មិនទេ ។

ជាតិ ៖ ចុះជំនាន់ខ្មែរក្រហម ម៉ាខែជួបមេឃុំប៉ុន្មានដង?

និន ៖ ណាត់គ្នាម៉ាខែ២ដងនេះ មកជួបមេឃុំយើងឥឡូវនេះទេ ។ តែកាលនេះគេចេញចូល។ ម៉ាខែមិនទាន់ជួបហៅប្រជុំកន្លែងទៅណាផង ។

ជាតិ ៖ កន្លែងគេនៅណា?

និន ៖ អាកន្លែងគេនិយាយពី ។

ជាតិ ៖ ទីស្នាក់ការឃុំនៅកន្លែងណា?

និន ៖ ទីស្នាក់ការស្រុកនោះ ស្នាក់ការឃុំនៅថ្នល់បំបែក កន្លែងនឹងភ្លើងឆេះអស់ទៅហើយ ។

ជាតិ ៖ តែប្រជុំភាគច្រើននៅទីស្នាក់ការស្រុក?

និន ៖ ប្រជុំវាប្រាប់មិនទៀង អាប្រជុំហៅមានកន្លែងមានតែទៅទីស្នាក់ការស្រុក តែឃុំគ្មានទេ ប្រជុំក្រោមម្លប់ឈើអី អានឹងសួរក្នុងភូមិ ។

ស៊ុយហៀង ៖ ឃុំអ្នកប្រជុំក្រោមម្លប់ឈើនឹង?

និន ៖ អឺ! អានឹងខាងមេឃុំ ។

ស៊ុយហៀង ៖ ឈ្មោះ ឆន នឹង?

និន ៖ បាទ!

ស៊ុយហៀង ៖ ហើយចុះពេលលោកតាដែលបានប្រជុំធំទេ ប្រជុំធំជាមួយខាងស្រុក ។

និន ៖ ប្រជុំធំជាមួយស្រុកអានឹងគេហៅ ។

ស៊ុយហៀង ៖ អានឹងគេប្រជុំនៅណា?

និន ៖ នៅត្រពាំងរុន ។

ស៊ុយហៀង ៖ នៅត្រពាំងរុននឹងម៉ង?

និន ៖ បាទ!

ស៊ុយហៀង ៖ កន្លែងក្នុងវត្ត?

និន ៖ មិនក្នុងវត្តទេ ក្នុងព្រៃ ។

ស៊ុយហៀង ៖ មានព្រៃដែរ?

និន ៖ ព្រៃឈើភូមិ ។

ស៊ុយហៀង ៖ ពីណាគេ អ្នកមកនិយាយធំជាងគេនៅក្នុងអង្គប្រជុំ?

ងិន ៖ មិនស្គាល់ទេ មិនចាំ ។

ស៊ុយហៀង ៖ កាលនោះប្រហែលប៉ុន្មាននាក់ទៅ ប្រជុំនឹង?

ងិន ៖ ទៅប្រជុំនោះវាមាន៨-១០-២០នាក់ក៏មាន ។

ស៊ុយហៀង ៖ សុទ្ធតែមេភូមិ?

ងិន ៖ មិនសុទ្ធ អានេះមានមេភូមិខ្លះ វាមានដូចថា...(ស្តាប់មិនបាន)ខ្លះទៅ ។

ស៊ុយហៀង ៖ មិនមែនគណៈស្រុកគេមកប្រជុំទេ?

ងិន ៖ ស្រុកគេមកប្រជុំ ។

ស៊ុយហៀង ៖ គេនិយាយពីអី?

ងិន ៖ ហ៎! មិនចាំទេ យូរពេកចឹង បោះបង់ចោលដឹងប៉ុន្មានឆ្នាំ៣០-៤០ឆ្នាំមក ។

ស៊ុយហៀង ៖ លោកតាអត់ដែលនិយាយសោះ?

ងិន ៖ អត់ មិនដឹងនិយាយពីគេម៉េចអត់ បោះបង់ចោល ។

ជាតិ ៖ ឋានៈអ៊ំជាជនចំរើន ហើយជនបង្គោល ឬបក្សជន?

ងិន ៖ កាលនឹង វាគ្រាន់ថាភូមិឃុំគ្មានបង្គោលគ្មានស្អី ។

ជាតិ ៖ ជនចំរើន?

ងិន ៖ អត់មិនដឹងគេហៅម៉េចទេ កាលនឹងគ្រាន់តែបង្គោលអត់ទេ អត់ដល់ ។

ជាតិ ៖ អត់ដល់បង្គោលទេ?

ងិន ៖ មិនដល់សម្ព័ន្ធដល់អីទេ តែគេប្រជុំនឹងដាច់ហើយ គេអត់ហៅ ។

ជាតិ ៖ ប្រជុំបក្ស ដល់សម្ព័ន្ធបានចូលបាន?

ងិន ៖ បាទ! អានេះគ្រាន់ជំនួសឲ្យមាននៅក្នុងភូមិ ដំណើរវាចឹង ។

ជាតិ ៖ ប៉ុន្តែធម្មតាមេភូមិ ជាជនចំរើន ក៏ជនបង្គោលដែរ បានគេឲ្យធ្វើ?

ងិន ៖ បាទ! វាមាន២ មានអាតូចៗជាងគេហើយ ដល់ភាគច្រើនគេហៅ បើថាតិចតួចគេមិនឲ្យទៅបៀតគេដែរ គេមានកន្លែងគេ គ្នាតូចគ្នាធំៗ ដូចថាការងារគេចាំបាច់ហៅគេទៅ ។

ជាតិ ៖ ចុះមេឃុំគាត់ជាបក្សជន គាត់ជាស្អី?

ងិន ៖ មេឃុំផ្នែកចូលៗបក្សជន ឥឡូវវាចូលបក្សអីនោះ អានឹងវាមានបក្សមានជនបង្គោលជនអីដូចតែគ្នានឹង បើតាមគិតទៅ ប៉ុនដល់អាគន្ធាក់ឃុំយើងទៅអត់ដល់ ។ បានត្រឹមតូចៗ ។

ជាតិ ៖ អ៊ំឆ្នាំ៧០ អ៊ំអត់ដែលបានចូលសម្ព័ន្ធយុវកក?

និន ៖ អត់ទេ អត់ទាន់ដល់ទៅនឹង ។

ស៊ុយហៀង ៖ ក្នុងភូមិអ៊ំមានបាត់មនុស្ស បាត់អី?

និន ៖ អត់ ។

ស៊ុយហៀង ៖ ចុះពេលរៀបការវិញ ពីណាគេអ្នកចាត់តាំងអានឹង?

និន ៖ រៀបការ អានឹងបើតាមតាំងពីនឹងមក វាមានខ្ញុំការម៉ាគូ២គូដែរ ការឲ្យ ។

ជាតិ ៖ តិចម៉េច?

និន ៖ អានឹងដូចថាដល់នេះទៅកន្លែងដែលហៅថា កងក្រុមគេទៅដាច់ពីយើង ដាច់ពីក្នុងភូមិ អានឹងយើងមានក្រុមគេ ខាងឃុំខាងស្រុកគេការឲ្យម៉ង ។

ស៊ុយហៀង ៖ មិនមែនលោកតាទេ?

និន ៖ អឺ! មុនដំបូងក្មួយៗគេមក គេឲ្យនិយាយត្រឹមត្រូវវាការបាន២គូដែរការនៅនឹងភូមិនឹង ដល់រួចពីនឹងទៅដាច់ទៅនៅលើក្រុមគេ កងគេ ។

ស៊ុយហៀង ៖ ចុះមន្ទីរម៉េចវិញលោកតា?

និន ៖ មន្ទីរពេទ្យ ។

ស៊ុយហៀង ៖ មានពេទ្យភូមិ?

និន ៖ ពេទ្យភូមិគ្មានទេ ។

ស៊ុយហៀង ៖ ពេទ្យឃុំមាន?

និន ៖ មានពេទ្យឃុំ មាន ។

ស៊ុយហៀង ៖ ពេទ្យឃុំនៅណាវិញ?

និន ៖ ពេទ្យឃុំនៅនោះដើមស្វាយ ប៉ុនគេកាប់ចោលបាត់ហើយ ។

ស៊ុយហៀង ៖ នៅលើដើមស្វាយនឹងម៉ង?

និន ៖ ហ្នឹង ក្រោមដើមស្វាយ ។

ស៊ុយហៀង ៖ ក្រោមដើមស្វាយ ពីណាគេអ្នកធ្វើកាន់ខាងពេទ្យនឹង?

និន ៖ ខាងពេទ្យនឹង រត់រតាត់រតាយ បាត់អស់ដែរនឹង ។

ស៊ុយហៀង ៖ មាននៅរស់ទេ លោកតានៅចាំមានអ្នកណានៅរស់?

និន ៖ នៅរស់នឹងគ្មាន មានតែទៅនៅឆ្ងាយៗ ។ យី! ភ្លេចទាំងឈ្មោះទៀតហើយមិនដឹងមីស្អីៗ ពេទ្យស្អីៗ ចូលយូរពេកទៅហើយ ។

ស៊ុយហៀង ៖ ពេលឈឺបញ្ជូនទៅពេទ្យក្រោមដើមស្វាយនឹង?

ងិន ៖ នឹងហើយ ។

ស៊ុយហៀង ៖ ហើយជា?

ងិន ៖ មានជា មានមិនជាចឹងដែរ ។

ស៊ុយហៀង ៖ ហើយបើអត់ជាម៉េចទៅ?

ងិន ៖ ដល់អត់ជាស្លាប់ទៅ ។

ស៊ុយហៀង ៖ អត់មានបញ្ជូនទៅពេទ្យស្រុក ពេទ្យអីទៀត?

ងិន ៖ យើងមានដែរ អានឹងដូចថាគេមើលមិនបានគេបញ្ជូនទៅស្រុកដែរ ។ បើថានេះ ជួនកាលវាឈឺស្លាប់នៅនឹងដែរ ។

ស៊ុយហៀង ៖ ហើយបើសិនជាមានអ្នកស្លាប់មានអីចឹងទៅ ពីណាគេអ្នកប្រមូលទៅកប់?

ងិន ៖ គ្មានគេ ។

ស៊ុយហៀង ៖ ខាងពេទ្យអ្នកចាត់ចែង?

ងិន ៖ អឺ!

ស៊ុយហៀង ៖ ពេទ្យនឹងមានគ្នាប៉ុន្មាននាក់លោកតាដឹងទេ?

ងិន ៖ ពេទ្យនៅនឹង៣-៤នាក់ ។

ស៊ុយហៀង ៖ ៣-៤នាក់ ស្រីៗទាំងអស់?

ងិន ៖ ស្រីៗ ។

ស៊ុយហៀង ៖ ដល់ពេលស្លាប់ទៅខាងស្រីប្រមូលទៅកប់ដែរ?

ងិន ៖ អឺ! ស្រីៗនឹងទៅដែរ គ្នាគាត់ ។

ស៊ុយហៀង ៖ ពេទ្យនឹងឈ្មោះអី ឈ្មោះវាឈ្មោះអី?

ងិន ៖ ហ៎! ភ្លេចហើយ ។

ស៊ុយហៀង ៖ មិនមែនពេទ្យឃុំ?

ងិន ៖ គេចាំមិនដឹង មីអីនៅលិច ពេទ្យហ៊ុនមួយ ពេទ្យយ៉ន់មួយ ។

ស៊ុយហៀង ៖ ចុះលោកតាថាមានវត្តមួយនៅ ថាមានវត្តអីគេយកមកធ្វើជាពេទ្យស្រុក វត្តនៅជិតនឹង ត្រពាំងរុន?

ងិន ៖ ដាក់ពេទ្យស្រុក ។

ស៊ុយហៀង ៖ អានឹងសម្រាប់តែកើតកូន ឆ្លប?

និន ៖ ហ៎! ពោធិ៍តាអង្គនោះ ។

ជាតិ ៖ ពោធិ៍តាអង្គ ហ្នឹងពេទ្យស្រុក?

និន ៖ ពេទ្យស្រុកទេ ។

ស៊ុយហៀង ៖ លោកតាមានស្គាល់ពីណាគេធ្វើការនៅនឹង?

និន ៖ មិន ។

ស៊ុយហៀង ៖ អត់ស្គាល់ ។ ចឹងលោកតាភាគច្រើនមានដឹងថា ថ្នាំកាលពីជំនាន់នឹងវាមានធ្វើពីអីដែរ មានថ្នាំពេទ្យបារាំងអីទេ?

និន ៖ ថ្នាំពេទ្យថ្នាំអីអត់ដឹងទេ មិនបេះ ។

ស៊ុយហៀង ៖ អត់ដឹង លោកតាដែលឈឺទៅញាំថ្នាំនៅពេទ្យនឹង?

និន ៖ ថ្នាំមានហូបមានអីដែរ គេធ្វើមានក្របមានអីត្រឹមត្រូវ ដូចថ្នាំយើងឥឡូវនេះចឹងដែរ ប៉ុនគេថាវា គេហៅថាថ្នាំជំនាន់នោះហៅថ្នាំអាចម៍ទន្សាយ ។

ស៊ុយហៀង ៖ គេផ្សំមកពីអីលោកតាដឹង?

និន ៖ វាគ្មានស្រោមគ្មានស្អីនឹង ។

ស៊ុយហៀង ៖ លោកតាធ្វើមេភូមិ លោកតាមានដឹងពីគុកផ្សេងៗទៀតទេ?

និន ៖ អត់ដែរ ។

ស៊ុយហៀង ៖ ចុះលោកតាថាគុកនៅវត្តអង្គរុន?

និន ៖ អាគុកនឹងគ្រាន់តែឮទេ អត់បានឃើញសំបុរគេម៉េចផងទេ ។

ស៊ុយហៀង ៖ លោកតាដឹងថា នៅនឹងគេចាប់អ្នកម៉េចខ្លះទៅ ទ័ពឬមួយក៏អីគេ?

និន ៖ ទេ! អារឿងចាប់ថាទ័ពក៏វាមិនចំថាពស្រ្តវាមិនចំដែរ ។

ស៊ុយហៀង ៖ ដាក់ទាំងអស់?

និន ៖ អត់ ។

ស៊ុយហៀង ៖ ធំទេលោកតា គុកនឹង?

និន ៖ មិនធំទេ បើតាមនិយាយទៅឮថាផ្ទះៗម៉ាល្វែង ។

ស៊ុយហៀង ៖ ហើយមានអ្នកកាន់កាប់នៅនឹង?

និន ៖ មានគេៗថាគេ ។

ស៊ុយហៀង ៖ គេអត់មានវៃ មានអីនៅនឹងតើ សួរចម្លើយសួរអី?

និន ៖ អាវៃអាអីនឹង មិនដឹងយ៉ាងម៉េចទេ ។

ស៊ុយហៀង ៈ ចុះលោកតាដែលមានព្យុគុកវត្តព្រះធាតុទេ?

ងិន ៈ ព្យុ ។

ស៊ុយហៀង ៈ ព្យុពីជំនាន់នឹង ឬមួយព្យុជំនាន់ណា?

ងិន ៈ នៅជំនាន់នឹងដូចតែគ្មានឹង ។

ស៊ុយហៀង ៈ ជំនាន់នឹងលោកតាព្យុដែរ?

ងិន ៈ ក៏ព្យុដែរ ប៉ុនគ្រាន់ដឹងថានៅវត្តនឹងៗដឹង ចំពោះបុគ្គលវាមិនស្គាល់ ព្យុតែកន្លែងវត្ត ។

ស៊ុយហៀង ៈ ចុះគេថាមនុស្សម៉េចទៅ បានគេចាត់ចូលនៅក្នុងគុកនឹង?

ងិន ៈ ទេ! អានឹងវាមិនដឹងយ៉ាងម៉េចខ្លះទេ យើងថាវាខុសទៅ ក្រែងនិយាយចាប់ផ្ដាក់ថា គេចាប់តែងវាខុស អានឹងវាគេថាយើងខុស បានគេចាប់ ហើយតែវាដឹងយើងខុស ពិតឬមិនពិត ជំនាន់នោះវារកកន្លែងពិតអត់ឃើញទេ ។

ស៊ុយហៀង ៈ ចុះអ៊ំមានព្យុអីផ្សេងទៀត ទាក់ទងនឹងវត្តព្រះធាតុ?

ងិន ៈ គ្មានមាន ។

ស៊ុយហៀង ៈ អត់មាន?

ងិន ៈ បាទ! មានច្រើនផ្នែកខាងខ្ញុំវាច្រើននៅតែស្រែៗប្រឡាយ ។

ជាតិ ៈ អ៊ំមេភូមិចឹង អ៊ំធ្វើស្រែជាមួយប្រជាជនដែរ?

ងិន ៈ បាទ! ធ្វើស្រែជាមួយគ្នា ។

ជាតិ ៈ មិនមែនបញ្ជាឲ្យគេធ្វើ?

ងិន ៈ មិនទេ គេក៏ធ្វើយើងក៏ធ្វើ ប៉ុនភាគច្រើន យើងវាច្រើនមុខជាងគេទៀតហើយ ។

ជាតិ ៈ ច្រើនមុខម៉េច?

ងិន ៈ ច្រើនមុខម៉េច ដូចថាម៉ាស្រែវាមិនចំម៉ាស្រែទេ ជួនគេហៅមកផ្ទះនេះខ្វះខាតរឿង អង្ករ ស្លឹកគ្រៃ អានឹងត្រូវមិត(រត់)មករក ។

ជាតិ ៈ បាទ! ត្រូវមកដោះស្រាយ?

ងិន ៈ បាទ! ដោះស្រាយ វាមិនចំម៉ាមុខៗទេ ស្រែម៉ាខែ៣០ថ្ងៃពិតហើយ ស្រែនន្គ័ល នឹង ។

ជាតិ ៈ គេមានឲ្យ១០ថ្ងៃសម្រាកម្ដងទេ?

ងិន ៈ ហ៉េ! អា១០ថ្ងៃនឹងគ្មានទេ ១០ថ្ងៃនឹង បើចេញទៅធ្វើស្រូវប្រាំងអានឹង១០ថ្ងៃឲ្យ ឡើងមកផ្ទះម្ដង ។

ជាតិ ៖ តែនៅក្នុងភូមិអត់មាន?

និន ៖ នៅក្នុងភូមិគ្មានសម្រាកគ្មានស្អី ទៅរាល់តែថ្ងៃ។

ជាតិ ៖ អត់មាន១០ថ្ងៃ មានបន្ថែមមានអី?

និន ៖ គ្មាន យើងចង់ធ្វើថ្ងៃណាចង់ធ្វើទៅ ដូចថាមានស្ករត្នោតស្ករអី យើងធ្វើៗឯកភាពគ្នាធ្វើ។

ជាតិ ៖ ចុះបើសិនជាអ៊ំចង់កាប់ជ្រូកមួយ អ្នកណាគេអ្នកសម្រេច?

និន ៖ ដល់គេសម្រេចឲ្យ។

ជាតិ ៖ អ្នកណាគេសម្រេច?

និន ៖ ឃុំ ដូចថាយើងមិនសម្រេចពីនឹងមក ថាយើងលួចទៀត។

ជាតិ ៖ តែនៅក្នុងឃុំមួយៗត្រូវមានចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចង់កាប់មាន់មួយអ៊ំអ្នកសម្រេចឬមួយក៏សុំឃុំ?

និន ៖ អាមាន់ទាបនៅក្នុងភូមិ។

ជាតិ ៖ មាន់ទាប ភូមិសម្រេចបាន?

និន ៖ បាទ!

ជាតិ ៖ ចុះជ្រូក?

និន ៖ ដល់ទៅជ្រូក ដល់ទៅគោ ដល់គេសម្រេចឲ្យ តែមិនចឹងគេថាយើងចោរ។

ស៊ុយហៀង ៖ ដែលមានលោកតា ដែលកើតរឿងចឹង មានន័យថា?

ជាតិ ៖ អ៊ំអ្នកសម្រេចអីមួយ?

និន ៖ ឲ្យមានទោស អត់។

ស៊ុយហៀង ៖ ហ្នឹងគេប្រាប់អ៊ំម៉ង ឬមួយអ៊ំដឹងដោយខ្លួនឯង គេប្រាប់ថាចង់កាត់នឹង?

និន ៖ អានឹងគេប្រាប់ ព្រោះអានឹងទៅដល់គោក្របីនឹងគេដាក់រួមហើយ យើងចេញទៅធ្វើការស្រែភ្ជួរទៅគេដាក់រួមមក អានឹងគេចាត់តាំងអ្នកមើលគោ បើថាគោនឹងម៉េចមួយម៉េចពីរតាំងពីឈើឡើងត្រូវរាយការណ៍ប្រាប់គេឲ្យដឹង។

ជាតិ ៖ រាយការណ៍ប្រាប់អ្នកណាគេ?

និន ៖ ប្រាប់មេឃុំគេ។

ស៊ុយហៀង ៖ ចុះមានពីណាគេនៅក្រោមបញ្ជាលោកតា?

និន ៖ ក្រោមបញ្ជាខ្ញុំ មានប្រជាជន។

ស៊ុយហៀង ៖ ចឹងលោកតានៅក្នុងភូមិលោកតា មានគេលួចអីវ៉ាន់លួចអី មានហ៊ានលួចដំឡូង លួចអីញ៉ាំចឹង?

ងិន ៖ អាដំឡូងអាអីយកស៊ីចឹង ប៉ុនវាគ្មានអី អានឹងជាធម្មតា ។

ស៊ុយហៀង ៖ តែលោកតាអត់មានរាយការណ៍រាយអី?

ងិន ៖ អានឹងគ្មានស្អីសោះ ។

ជាតិ ៖ បើសិនជាចេះ ក្នុងភូមិអ៊ំមានអ្នកចោរលួចគោ អ៊ំទៅប្រាប់អ្នកណាគេឲ្យមកចាប់ចោរនឹង?

ងិន ៖ អាចោរលួចគោនឹង និយាយឲ្យត្រង់ទៅមានចោរនឹងកាប់គោស៊ីមាន តែគ្មានចោរនោះលួចដឹងទៅណា គ្មានទេ ។

ជាតិ ៖ កាប់គោស៊ីម៉ង?

ងិន ៖ កាប់គោស៊ីម៉ង អានឹងគេមករកឃើញខ្លួនគេ ។

ជាតិ ៖ គេមករកឃើញខ្លួនគេ?

ងិន ៖ អឺ! គ្រាន់តែប្រាប់គេថា ឥឡូវគោបាត់ៗ ចុះគោនឹងចុះឯណា ចេះបាត់យកទៅកាប់ក្រោមភូមិដើង ។ ហើយចឹងគេជួយតាមរកៗ គេរកទាល់តែឃើញ ។

ជាតិ ៖ ពីណាគេអ្នកកាប់?

ងិន ៖ អាឡាងគេឈ្មោះវាពិន កាលនឹង ប្រជាជនវេលាជំនាន់នោះគេនិយាយប្រជាជន ១៧ ។

ជាតិ ៖ អានោះនៅរស់ទៀត?

ងិន ៖ ងាប់ តែគេរកឃើញចឹង ដែលនៅ គេចាប់យកទៅបាត់ គេគ្មានទៅធ្វើម៉េចឲ្យយើងឃើញ គេនាំទៅបាត់ ។

ស៊ុយហៀង ៖ លោកតាដឹងថាគេនាំទៅណា?

ងិន ៖ អានឹងមិនដឹងគេនាំទៅណា យកទៅដឹងយកទៅណា គេគ្មានប្រាប់យើង ។

ជាតិ ៖ ហើយចុះខុទាហរណ៍ថាឃុំគេត្រូវបញ្ជូនឈ្លបមកស៊ើបការណ៍ ភូមិអ៊ំនេះ?

ងិន ៖ ហ្នឹងហើយគេឡើងចុះរាល់ថ្ងៃ ។

ជាតិ ៖ គេប្រាប់អ៊ំមុនទេ ពេលមក?

ងិន ៖ គេមិនប្រាប់ទេ ។

ជាតិ ៖ គេអត់ប្រាប់?

ងិន ៖ អត់ ។

ជាតិ ៖ ចូលភូមិអុំមិនចាំបាច់ប្រាប់?

ងិន ៖ មិនបាច់ទេ ព្រោះអានឹងគេដើរមើលរាល់ថ្ងៃចឹង គេសម្ងាប់នៅនឹង ។

ស៊ុយហៀង ៖ អុំដែលឃើញឈ្លបឃុំនឹង ចាប់អ្នកភូមិចាប់អី?

ងិន ៖ កន្លែងនេះគ្មានទេ គ្មានដែលខូចខាតណាមួយ ។ ឥឡូវមកសួរខ្ញុំមេភូមិឥឡូវនឹង ហើយមេភូមិកាលនោះ ក្រែងខ្ញុំនិយាយកុហក ចឹងសួរប្រជាជនក្រោយនេះវិញ ។ តើប្រជាជនភូមិនឹងមានខូចខាតទេ ។

ជាតិ ៖ សួរតែអុំបាន?

ងិន ៖ បើសួរខ្ញុំៗចេះកុហក ។

ជាតិ ៖ អុំចុះពីណាគេ ប្រធានយុវជនឃុំ?

ងិន ៖ ប្រធានយុវជនឃុំនៅឆ្ងាយៗស្លាប់បាត់ ។

ជាតិ ៖ ឈ្មោះអីដែរ?

ងិន ៖ ច្រើនតែឈ្មោះៗ ជា ។

ស៊ុយហៀង ៖ គាត់នៅណាដែរ?

ងិន ៖ ឥឡូវនេះស្លាប់បាត់ ។

ជាតិ ៖ អុំនៅក្នុងភូមិ គ្រប់គ្រងយុវជនដែរអត់ទេ ឬគ្រប់គ្រងតែស្រ្តីកសិករ?

ងិន ៖ ម៉ាជំនាន់នោះ មុនដំបូងគ្រប់គ្រងទាំងអស់ តាំងពីញាស់ រហូតចាស់ ។ ដល់៧៥ ៧៦នឹង វាទៅតាមដោយឡែកចែក នៅតែយាយចាស់ៗ(សើច) ។ នៅក្នុងភូមិ មានតែយាយចាស់ៗ ក្មេងៗតាមកងតាមស្រុកគេបាត់អស់ហើយ ។

ស៊ុយហៀង ៖ ចឹងលោកតាអត់មានសិទ្ធិទៅគ្រប់គ្រងកងនឹងទៀត?

ងិន ៖ អត់ៗមានចូលកង តែកងនឹងប្រជាជនក្នុងភូមិ ។

ជាតិ ៖ តែរបៀបគ្រប់គ្រងវាខុសគ្នាម៉េច អាពីដំបូងរហូតដល់ឆ្នាំ៧៧ ៧៨ ដំបូងអុំគ្រប់គ្រងក្នុងភូមិ ក្រោយមកគេបង្កើតសហករណ៍រួមភូមិ រួមឃុំ?

ងិន ៖ រួមភូមិ រួមឃុំ ។

ជាតិ ៖ អុំធ្វើអី?

ងិន ៖ ខ្ញុំនៅភូមិដដែល ។

ជាតិ ៖ តែអុំដឹកនាំ?

និន ៈ អានឹងវាដឹកនាំប្រជាជននៅក្នុងភូមិចឹងទៅ ដូចថានៅសល់តែចាស់ៗនឹង ដល់វាត្រូវបែកសហករណ៍រួមឃុំនឹង គេដកកម្លាំងពេញ ទៅគេគ្រប់គ្រងដោយខ្សែកខាងគេខាងឃុំនោះ ។

ជាតិ ៈ តែអ៊ំធ្វើអីកាលនឹង?

និន ៈ កាលនឹងខ្ញុំនៅភូមិដដែល ។

ជាតិ ៈ តែដឹកនាំកង?

និន ៈ ដឹកទេ! ថាកងនឹងមិនកង អានឹងគេហៅនៅភូមិ ចាំភូមិ ។ អាកងនឹងគេហៅចេញមកតាមកងចល័ត កងស្អីគេណានោះ អានឹងបានចេញទៅតាមកង តែនៅភូមិគេមិនហៅកងទេ ។ គេហៅភូមិនឹងម៉ង ។

ជាតិ ៈ អ៊ំដឹកនាំពីណាគេវិញ?

និន ៈ បាទ?

ជាតិ ៈ ដឹកនាំប្រជាជនដែរ?

និន ៈ ប្រជាជនដែរ ។

ស៊ុយហៀង ៈ ចុះបន្ទាប់មកទៀតលោកតាពេក៧៩ហើយចប់ លោកតាភៀសទៅណាវិញ?

និន ៈ ៧៩ចប់ ។

ស៊ុយហៀង ៈ ពេលវៀតណាមចូលមក?

និន ៈ ៧៩ចប់ មកពី៧៩មិត(រត់) និយាយឲ្យចំរត់ៗដល់៧៩វាបែកចូលផ្ទះ ។ មកចូលផ្ទះវិញ ។ កាលពី៧៩យើងមិនរត់រគាតពេញដី អានឹងវៀតណាមចូលៗមកវានៅប្រទុងប្រទាញគ្នាត្រូវតែរត់ទាំងអស់គ្នា ។

ស៊ុយហៀង ៈ រត់ទៅណាវិញ?

និន ៈ រត់ទៅលើៗ ។

ស៊ុយហៀង ៈ លើនឹងណាទៅ?

និន ៈ ទៅចឹងៗតានី ទៅគេហៅខាងលិចអន្លុតាសោម ។

ស៊ុយហៀង ៈ លោកតាទៅនៅនឹងបានយូរ?

និន ៈ ទៅនៅបានម៉ាខែ២ដែរ ។

ស៊ុយហៀង ៈ ហើយដើរមកវិញ?

និន ៈ ដើរ ។

ស៊ុយហៀង : លោកតារត់ទៅៗនឹង រត់ទៅជាមួយកងទ័ព ឬមួយម៉េចដែរ?

និន : ជាមួយប្រជាជនទូទៅ ។

ស៊ុយហៀង : ហើយទៅដល់នឹងរស់នៅម៉េចដែរ ហូបចុក?

និន : ធម្មតា អានឹងរស់នៅវាកាលនោះ វាមិនទាន់ស្ទួតត្រង់ វាមិនទាន់របស់អញ របស់ឯងទេ ។ ទៅដល់កន្លែងនោះ វាមានទៅឲ្យកើបស្រូវ ចែកអង្ករឲ្យហូបចឹងដែរ ។ ទាល់វិលមកវិញៗ នៅតែគេរកគេកើបគេច្រូតអី មានស្រូវជុំៗនៅក្នុងក្រាំងអីចែកគ្នាមក ។

ស៊ុយហៀង : លោកតានៅតាមផ្លូវពេលរត់ទៅ លោកតាមានឃើញមនុស្សស្លាប់ មនុស្សគេចាប់ ឬមួយទាហានគេបាញ់គ្នា ឬមួយម៉េច? លោកតាអាចរៀបរាប់ទិដ្ឋភាពនឹងបានទេ?

និន : មិនកើតទេ វាមិនដែលបានឃើញ មិនដែលបានយល់ ។

ស៊ុយហៀង : ពេលលោកតារត់ មិតទៅលើ?

និន : ហ្នឹងហើយ មិតទៅនឹង អត់ដែលបានបាញ់អីគ្នាអត់ ។ អានឹងវាឮដោយសារខ្យល់ វាពិបាកឮដល់យើងភ័យ យើងចេះចាំ ។

ស៊ុយហៀង : ចឹងពេលលោកតាទៅដល់នឹងហើយ មកវិញ លោកតាម៉េចដែរ មកវិញលោកតាអាចនិយាយរៀបរាប់ទិដ្ឋភាពពេលនឹង មានកូនក្មេងមានមនុស្សចាស់ម៉េចទៅ ហើយចាស់រូបភាពម៉េចដែរ?

និន : ទេ! មកវិញ ខ្ញុំមកវិញនឹង វាគ្មានឃើញស្អី ដូចថាខ្មោចទ័ព ខ្មោចស្អី វាមានឃើញនៅស្លាប់តាមផ្លូវតាមអីវាមានមែនៗ វាមានឃើញ ត្រង់ស្លាប់នឹងវាព្រាត់ប្រាសយ៉ាងម៉េចមួយ យ៉ាងម៉េច២យើងក្តាប់វាអត់បាន ដឹងតែដាច់ពោះ ហើយក៏គេសម្លាប់ក៏វាក្តាប់អត់បានដែរ ។

ស៊ុយហៀង : ចឹងពេលលោកតាមកដល់វិញ លោកតានៅភូមិនឹងដដែល?

និន : បាទ! ដល់រត់មកដល់ភូមិវិញ មកនៅនឹងវិញដដែល ។

ស៊ុយហៀង : ភូមិជំរះនឹងដដែល?

និន : បាទ!

ស៊ុយហៀង : ហើយបន្ទាប់មកទៀត ឆ្នាំណាលោកតាមកធ្វើមេភូមិទៀត?

និន : ដល់មកឡើងមេភូមិក្រោយនេះ មើល៨៣គេឲ្យធ្វើក្រុមដដែល យើងឆ្លងកាត់ចូល

មកវិញ មិន៧៩ ៗ ជ័យជំនះមកវត់ដល់ខែ២ខែ៣ បានចូលមកដល់ផ្ទះក្រោយគេ ។ ហើយចឹងមកដល់នឹង៨៣ គេឲ្យធ្វើក្រុមវិញហើយ ។

ជាតិ : ក្រុមវិញ?

ងិន : អឺ!

ជាតិ : ក្រុមទៀត?

ងិន : ធ្វើក្រុមទៀត ។

ស៊ុយហៀង : កាន់ប៉ុន្មាននាក់ទៅ?

ងិន : ដល់កាលនឹងក្រុមមានតែ១៥នាក់ទេ ។

ជាតិ : អត់ទាន់មានអ្នកមកច្រើន?

ងិន : អឺ! មកដល់នេះហើយ ។

ស៊ុយហៀង : ពីណាគេឲ្យអ៊ំកាន់?

ងិន : ឥឡូវនឹងប្តូរៗទៅត្រឡប់ត្រឡិន នៅមួយដែរប៉ាក់ពើកព្យាបាល៣និយាយមិនច្បាស់ នាំតាយ៉ក នាំអ្នកគុណនឹង ។ បានមកដល់៨៦ ៗ បានដល់ភូមិវិញ ។

ស៊ុយហៀង : លោកតានៅចាំទេ លោកតានៅ៨០ជាង លោកតាកាន់ក្រុមអីនឹង លោកតាដែលមានពុញ្ញតិរណសិរ្សអី?

ងិន : ទេ! ដាច់ម៉ាត់ គ្មានធ្វើស្អី ។

ស៊ុយហៀង : គេប្រមូល ដូចថាលោកតាមានដឹងថាជំនាន់នឹងដូច៨០ជាង គេមានឲ្យអ្នកភូមិសរសេរ រឿងរ៉ាវឈឺចាប់របស់ខ្លួនឯង?

ងិន : ប្រវត្តិ ។

ស៊ុយហៀង : សរសេរនៅក្នុងញាតិនឹង លោកតាមាននៅចាំ?

ងិន : អត់ទេ ។

ស៊ុយហៀង : អត់មាន?

ងិន : អឺ!

ស៊ុយហៀង : អត់មានអ្នកណាគេចុះមករដ្ឋាភិបាលឲ្យយើងសរសេរ លោកតាមានចាំ?

ងិន : គ្មាន មិនដែលបានជួបបានសរសេរ បានអីនិយាយពីអីអត់ទេ នៅក្នុងភូមិយើង ធម្មតា គាត់ប្រជុំថាកុំភ្លេចខ្មែរក្រហម កុំភ្លេចរឿងកំហឹងរបស់យើង អានឹងមានៗ

ប្រជុំៗ តែមកសរសេរមកអីឡើងទៅលើញ្ញត្តិនោះ គ្មានទេៗ កោះធ្វើ ដូចថាគេតម្រិះជ្រៅជាងយើង គេធ្វើទៅ។

ស៊ុយហៀង : លោកតា ខ្ញុំសុំសួរត្រឡប់ក្រោយតិច ទាក់ទងនឹងឆ្នាំ៧០ជាង លោកតាធ្វើមេក្រុមនៅជំនាន់លន់ នល់អីចឹងៗ ពេលលោកតាចូលដល់ខ្មែរក្រហមចឹង ខ្មែរក្រហមអត់ឆ្ងល់ទេ លោកតាធ្លាប់ធ្វើជាមួយលន់ នល់អីចឹង?

ងិន : ហ៎! គេឆ្ងល់ដែរ។

ស៊ុយហៀង : ហើយម៉េចទៅ បានគេឲ្យលោកតាធ្វើមេក្រុមទៀត?

ងិន : គេសួរៗថា តើជំនាន់លន់ នល់អាម៉េច ធ្វើស្អី ថាធ្វើក្រុមៗ ធ្វើក្រុមអត់ៗមានស្អីគេគ្រាន់តែសួរប៉ុននឹងៗ ប៉ុនសួរនឹង មិនមែនសួរតែម្ដងទេ សួរ២-៣ដងដែរ។

ស៊ុយហៀង : ម៉េចទៅ?

ងិន : សួរនឹងថាខ្ញុំធ្វើមេក្រុម ប៉ុនមេក្រុមកាលនោះមិនដឹងក្រុមម៉េចអីម៉េចទេ ប្រជាជនទៅប្រជាជន យើងនៅតែយើងដដែល រកស៊ីស្មើតែគ្នា មិនដឹងណាក្រុមនឹងម៉េចផង។

ស៊ុយហៀង : ព្រោះអីជួនកាលខ្មែរក្រហមខ្លាចថា ពីណាគេមានជាប់ពាក់ព័ន្ធនឹងលន់ នល់ចឹងវាសម្លាប់?

ងិន : វាត្រូវហើយ ជំនាន់នោះ ថាខ្លាចដូចជាមិនខ្លាច ខ្ញុំនិយាយត្រង់អានឹង គ្មានថាខ្លាចស្លាប់ហើយមិនស្លាប់នឹង នោះជាធម្មតា អត់មាននឹកថាខ្លាចស្លាប់អត់ រឿងយើងពីមុនប៉ុន្មាននិយាយប្រាប់គេដោយត្រង់ វាអត់អីៗ ដល់អត់អីចេះអត់រហូតទៅ។

ស៊ុយហៀង : ចឹងវាអត់ចេះសួរនាំយើងទៀត?

ងិន : អត់ៗ

ស៊ុយហៀង : ចឹងលោកតាមានស្គាល់មេភូមិផ្សេងៗទៀតធ្វើការជាមួយលោកតាកាលពីជំនាន់ខ្មែរក្រហមនឹង?

ងិន : មេភូមិៗ

ស៊ុយហៀង : ភូមិផ្សេងៗជិតនឹង?

ងិន : ភូមិផ្សេងៗ យី!ឥឡូវដូចជាស្លាប់បាត់អស់ហើយៗ

ស៊ុយហៀង : មានសល់១-២ លោកតាសាកគិតមើល?

ងិន : ត្រពាំងខ្នាយ ព្រៃរំដេង ហ្នឹងហើយស្លាប់ៗ

ស៊ុយហៀង : ចុះមេឃុំ?

ងិន ៖ មេឃុំ....(ស្តាប់មិនបាន) ។

ស៊ុយហៀង ៖ មេឃុំលែង អត់មាន?

ងិន ៖ មេឃុំលែង អត់មាន បាត់រលីងតាំងពី៧៩ បាត់រហូត ៧៨ ដល់៧៩ គ្មានឃើញមេឃុំណាមួយវិលមួយមកវិញ ។

ស៊ុយហៀង ៖ អត់មានមក?

ងិន ៖ អត់ អានឹងនៅជិតៗយើងអាចដឹងនឹង គ្មានវិលទៅៗបាត់ៗរហូត ម៉ារត់នោះធ្វើបាត់បែកគ្នាបណ្តោយ ។

ស៊ុយហៀង ៖ អត់មានអ្នកណារត់មកចូលផ្ទះ ស្រុកភូមិវិញ?

ងិន ៖ អត់ ។

ស៊ុយហៀង ៖ លោកតាសព្វថ្ងៃធ្វើអីដែរ?

ងិន ៖ ធ្វើអី ។

ស៊ុយហៀង ៖ ធ្វើមេភូមិ អត់មានធ្វើស្រែធ្វើអីទៀត?

ងិន ៖ អូ! ស្រែ បើតាមខ្ញុំគិតមេភូមិចំ ។

ស៊ុយហៀង ៖ មេភូមិចំ អត់ធ្វើស្រែធ្វើអី?

ងិន ៖ ស្រែធ្វើមិនកើត ដេកតែហូប ។

ស៊ុយហៀង ៖ មានកូនប៉ុន្មាននាក់លោកតា?

ងិន ៖ កូន៦-៧នាក់ដែរ ។

ស៊ុយហៀង ៖ ជំនាន់ខ្មែរក្រហមលោកតាមានកូនទេ?

ងិន ៖ មាន ។

ស៊ុយហៀង ៖ ប៉ុន្មាននាក់?

ងិន ៖ មាន៤ហើយ ។

ស៊ុយហៀង ៖ ហើយកូនៗទៅណាទៅកាលជំនាន់នឹង?

ងិន ៖ នៅវានៅចឹង ។

ស៊ុយហៀង ៖ នៅជាមួយកងផ្សេង?

ងិន ៖ នៅឲ្យវាកងទៅអីចឹងដែរ កងកុមារ កងអីនឹង មានទៅ អានឹងម៉ាដួរកងនឹង ។

ស៊ុយហៀង ៖ ចុះកាលនឹងលោកតានៅជាមួយប្រពន្ធនៅផ្ទះ ឬមួយប្រពន្ធនៅផ្សេង កូននៅផ្សេង?

និន ៖ បើនិយាយពីខ្ញុំវិញ វាអត់ទៀតទេ ជួនកាលប្រជុំទៅស្រែៗមានជិតមានឆ្ងាយ ជួនកាលមានចោលផ្ទះចឹងដែរ ។

ស៊ុយហៀង ៖ ប៉ុន្តែនៅជាមួយគ្នា?

និន ៖ នៅជាមួយគ្នាចឹងដែរ ។

ស៊ុយហៀង ៖ នៅផ្ទះជាមួយគ្នា?

និន ៖ បាទ!

ស៊ុយហៀង ៖ ចុះប្រជាជនធម្មតាវិញ បែកគ្នា?

និន ៖ អាធម្មតានឹង វាបើយើងធ្វើស្រែខាងក្រោមភូមិចឹង អានឹងជាធម្មតាយើង បើទៅជួយធ្វើស្រែប្រាំង អានឹងបែកគ្នា ស្រែប្រាំងគេធ្វើនៅគៀកទម្លាប់នោះ ។

ស៊ុយហៀង ៖ ភាគច្រើនគេបំបែកប្រពន្ធនៅផ្សេង ប្តីនៅផ្សេង?

និន ៖ អានឹងវាដូចបំបែកចឹង រឿងធ្វើស្រែប្រាំងនឹង បើមិនបំបែកក៏ដូចជាបំបែកចឹងដែរ ចុះបើស្រែនៅនោះហើយទៅមកៗ រឿងអីយ៉ាប់ដើរមិនរួច ។ ចឹងវាមាននៅដេកនឹងស្រែនឹង២-៣ថ្ងៃ ដូរទៅមកៗ ។

ស៊ុយហៀង ៖ ចុះលោកតា ជីវិតពីលោកតាជំនាន់ខ្មែរក្រហមធ្វើមេភូមិ ហើយឥឡូវធ្វើមេភូមិទៀត លោកតាគិតទៅថាពីរនឹង មួយណាវាម៉េចដែរ លោកតាគិតថាវាមានផ្លាស់ប្តូរឆ្ងាយច្រើនទេ?

និន ៖ ទេ! បើតាមគិតវាផ្លាស់ប្តូរ វាមានច្រើន ព្រោះវាជំនាន់នោះវាគ្មានរបបទេ ឥឡូវវាមានវាផ្លាស់ប្តូរចឹង ។ តែរកស៊ីជំនាន់នោះ បើយើងមិនធ្វើស្អី ផ្ទះអញ សិទ្ធិអញមេភូមិទៅហើយ មិនកាន់កាំបិត មិនកាន់ពូថៅក៏វាបានដែរ តែឥឡូវយើងដល់កាន់កាំបិតកាន់ពូថៅ គោ ក្របី បានវាមានហូប វាខុសគ្នាចឹង ។

ស៊ុយហៀង ៖ ចុះលោកតាថាមួយណាល្អជាង?

និន ៖ ទេ! ថាល្អវាមិនលើសទេ ។

ស៊ុយហៀង ៖ អត់មានលើសគ្នា?

និន ៖ បាទ! ប៉ុនថាវាឃើញថាខុសកាលនោះ វាខុសឥឡូវៗ គេរកកន្លែងមានកន្លែងយុត្តិធម៌សួររកចម្លើយ តែជំនាន់នោះគេមិនសួរទេ ដូចថាគេដឹងថាយើងខុស ឬមួយយើង ខុសដោយមិនដឹង គេអត់បាច់ប្រាប់ពីណាទេ ។

ស៊ុយហៀង ៖ ចាប់យកទៅម៉ង?

និន ៖ គេចាប់យកទៅម៉ង បើគេត្រូ គេដឹង ។

ស៊ុយហៀង ៖ ដែលមានករណីកើតឡើងក្នុងភូមិអ៊ំ?

និន ៖ មិនដែលករណីអីឲ្យវាខូចខាត អានឹងវា ។ អានឹងកាលជំនាន់នោះ បើតាមស្តាប់ទៅតែមានចាប់ អានឹងវាខូចខាតហើយ ។ តែប្រជាជននៅក្នុងកន្លែងនេះក៏មិនដែលមានចាប់អ្នកណាចេញទៅ១-២យប់អីគ្មាន ។

ស៊ុយហៀង ៖ លោកតាថាមានផ្លាស់ប្តូរខ្លះអី ផ្លាច់ប្តូរខ្លាំងទេ នៅក្នុងភូមិលោកតា?

និន ៖ ផ្លាស់ប្តូរពីជំនាន់នោះ ហើយឥឡូវ?

ស៊ុយហៀង ៖ ហ្នឹងហើយ?

និន ៖ ហ៎! បើតាមតែទិដ្ឋភាព ផ្លាស់ប្តូរ តែផ្លាច់ប្តូរថាវាមិនផ្លាស់ប្តូរទិដ្ឋភាព វាការរកស៊ីឃើញថាកាលនោះ វាគ្មានដូចថាយើងចង់បានអី មិនបានដូចឥឡូវទេ ទិដ្ឋភាពគេតម្រិះបញ្ញាគំនិតរបស់គេៗរកបាន ។ តែជំនាន់នោះវាគ្មានអ្នកណារកណាក្រៅពីសហករណ៍គេ ។

ស៊ុយហៀង ៖ ចុះលោកតា កាលពីចូលមក៧៩នឹង លោកតាមានឃើញគេចាប់ដូចថាអ្នកអតីតខ្មែរក្រហមគេយកវៃ លោកតាមានឃើញ?

និន ៖ គ្មានឃើញ ។

ស៊ុយហៀង ៖ អត់មាន?

និន ៖ បើតាមគិត ។

ជាតិ ៖ វៀតណាមមានមកចាប់អី?

និន ៖ បើសិនជាចាប់ គួរតែចាប់ខ្ញុំព្រោះខ្ញុំវាជាប់និន្នាការ វាគួរតែចាប់ខ្ញុំ ហើយខ្ញុំវាមិនដែលចាប់ដែលចង ដែលហៅអីទៅចូលឃុំចូលស្រុកផង ។

ជាតិ ៖ គេអត់ដែលហៅអ៊ំទៅសួរចម្លើយអី?

និន ៖ អត់ៗឈឹង ។

ស៊ុយហៀង ៖ ចឹងលោកតាគិតថាជាមួយអ្នកភូមិធម្មតា ហើយនឹងអតីតមិនមែនលោកតា ដូចថាអតីតខ្មែរក្រហមទូទៅ លោកតានៅក្នុងភូមិអីចឹង ពួកគាត់ម៉េចទៅល្អនឹងគ្នា ឬមួយម៉េចដែរ?

និន ៖ ទេ!

ស៊ុយហៀង ៖ ធម្មតា? អត់មានឈ្លោះគ្នា ប្រកាន់ទឹង សំបាលនឹងគ្នា?

និន ៖ អត់ទេ អត់ៗ

ស៊ុយហៀង ៖ អត់មានចង់សងសឹក សងអី?

និន ៖ គ្មាន អាចឹងបានថា ចង់សងសឹកចង់ចងគំនុំពួកខ្ញុំធ្វើការតាំងពីជំនាន់ខ្មែរក្រហម និងជំនាន់ឥឡូវនេះៗ យើងចូលមកដល់ គេមិនឲ្យធ្វើការក្នុងឥឡូវនេះភ្លាមទេៗ កាលពី៧៩ មកទល់នឹង៨៣ ឲ្យធ្វើត្រឹមក្រុមទេៗ អីចឹងគេទុកអានឹងតាមដានមើលទេ បើថាវាអាចឡើងរួចក៏ឡើងទៅ បើវាឡើងមិនរួចទេ វាចុះសូន្យទៅវិញហើយ អានឹងវាចឹងៗ ចឹងខ្ញុំចូលដល់ក្នុងភូមិ ខ្ញុំថាវាគ្មានរស់អី ព្រោះនិន្នាការរបស់យើងមិនមែនម៉ាជំនាន់ណា ១-២ជំនាន់ទៅហើយ គួរតែមិននៅៗ

ស៊ុយហៀង ៖ អត់ទេ ជួនកាលលោកតាធ្វើល្អអីចឹង?

និន ៖ ឥឡូវយើងអួតខ្លួនយើងក៏មិនហ៊ានថាដែរៗ

ស៊ុយហៀង ៖ អ្នកភូមិចូលចិត្តលោកតាទេ តាមលោកតាមើលទៅ?

និន ៖ តាមគិតទៅ អានឹងមិនចូលចិត្តនឹងយើងៗក៏គ្រប់គ្រងដល់ឥឡូវនេះក៏មិនបានដែរៗ ប៉ុន១០០ ១០០០ម៉េចក៏មិនអត់១-២ វាត្រឹមពាក្យសម្ដីតិចតួច អានឹងវាអនុគ្រោះគ្នាទៅវិញទៅមកបានៗ បើឥឡូវមិនស្ដីសោះក៏មិនកើត មិនថាសោះមិនកើតៗ

ស៊ុយហៀង ៖ ចុះលោកតាមានដឹង មានក្ដាប់បានថាមូលហេតុអី បានជាអ្នកភូមិយើងខ្លះ គាត់អត់មានវីងអីចឹង?

និន ៖ ទេ! ត្រង់នឹងៗ

ស៊ុយហៀង ៖ គាត់បងប្អូនគ្នាឬម៉េច?

និន ៖ វាមានបងប្អូនវាមាន អ្នកឆ្ងាយដូចថាវាញាតិស្រុក វាមិនសាច់ឈាមទេ ញាតិស្រុកក៏ស្គាល់នឹងចឹងទៅ អាមិនស្រុកស្គាល់ចឹងទៅៗ

ស៊ុយហៀង ៖ ព្រោះខ្ញុំឮភូមិជិតៗនឹង ចាប់អ្នកខ្លះកាចសាហាវពេកចឹង គេវ៉ៃចឹងៗ

និន ៖ បាទ! អានឹងវាមានចឹង យើងប៉ុនរាយការណ៍ ប៉ុនហៅគេមកចាប់មកចង អានឹងគេស្អប់គេខ្ពើម អានឹងវាត្រូវទៅសូន្យតាំងពីចុះមកនោះ បានម៉ាឆ្នាំអី ឬកន្លះឆ្នាំអីគេយកទៅបាត់ដែរនឹង អានឹងភូមិគេមាន ឮៗ

ស៊ុយហៀង ៖ ឮនិយាយ?

និន ៖ បាទ! ប៉ុន្មានមិនច្រើនទេ ៤-១០-២០-៣០ភូមិអីវាមានមួយ ច្រើនឃើញខូច ឮថារាមអណ្ដើកនឹង ខូចម្នាក់ដែរ ។

ពិចិត្រ ៖ ចុះលោកតាមានក្ដាប់បានថា ហេតុអីបានជាអ្នកភូមិដែលគាត់មិនមែនជាខ្មែរក្រហម ដូចជាគាត់បន្ទាប់ពីរបបនឹងចប់ មានន័យថាទៅរករឿងអ្នកធ្លាប់ធ្វើការពីសម័យមុនអីចឹង លោកតាមានក្ដាប់បានដោយសារមូលហេតុអី?

និន ៖ ទេ! អានឹងគ្រាន់តែគិតខ្លួនខ្ញុំ បើតាមក្ដាប់ពីគេ វាមិនអាចយកពីគេទេ បើតាមគំនិតរបស់យើង តែយើងធ្វើជំនាន់នឹងវាជ្រុលហួសពេក ។ ដល់ជ្រុលហួសពេក ដល់យើងត្រឡប់មកវិញ មានលើមានក្រោមហើយ ។ អីចឹងគេទ្រាំមិនបាន គេធ្វើបាបវិញ អានឹងបើតាមគំនិតរបស់ខ្ញុំទេ បើថាយើងធ្វើម៉ាល្មម ពាក្យសម្ដីនាយអាយតិចតួច អានឹងវាមិនបានដល់ចឹងអីទេ ។ អានឹងខ្ញុំវៃតម្លៃខ្លួនខ្ញុំ មិនវៃតម្លៃគេឲ្យផុតចុងផុតដើម ។

ស៊ុយហៀង ៖ ចឹងលោកតា សុំសួរមួយ ពេលជំនាន់នឹង គេមានគៀបសង្កត់លោកតាធ្វើអីធ្ងន់ធ្ងរខាងថ្នាក់លើ មានបញ្ជាឲ្យលោកតាធ្វើអីធ្ងន់ធ្ងរ?

និន ៖ ទេ!

ស៊ុយហៀង ៖ ឲ្យធ្វើស្រូវឲ្យច្រើនចឹង ឬមួយយ៉ាងម៉េច?

និន ៖ អារឿងធ្វើនឹង ធ្វើស្រែ ធ្វើស្រូវនឹង ។

ស៊ុយហៀង ៖ អត់មានអ្នកណាគៀបសង្កត់លោកតាទេ?

និន ៖ គ្មាន ធ្វើធម្មតាចឹង ។

ស៊ុយហៀង ៖ គេអត់បង្ខំឲ្យធ្វើបាន ឬមួយម៉េច ប្ដេជ្ញាម៉េច?

និន ៖ អាប្ដេជ្ញានឹង ពេលប្រជុំពេលអីគេថាប្ដេជ្ញាចឹងមែន ប្រជុំថាប្ដេជ្ញាធ្វើឲ្យបាន៣តោនទៅ៦តោននឹង អានឹងមានថា ប៉ុន្តែបើថាចុះបើផលស្រូវវាមិនបាន ។

ស៊ុយហៀង ៖ ធ្វើម៉េចទៅគេស្ដីឲ្យលោកតា បើអត់បាន?

និន ៖ ស្ដីឲ្យមិនបានវាទូទៅ ឃុំនៅធ្វើនឹង យើងប្រជាជនក៏នៅធ្វើនឹង អីចឹងឧទាហរណ៍ថាដីពីនឹងទល់ថ្នល់សុបិន្ត តែម៉ាឃុំទេ អានឹងរួមគ្នាទាំងអស់ធ្វើ គេអាយើងនៅតាមភូមិនេះ យើងធ្វើតាមភូមិចឹង គេក៏ចុះមកពិនិត្យលើយើងធ្វើនឹងដែរ ។

ស៊ុយហៀង ៖ លោកតាមានដឹងទេ ពេលឃុំធ្វើអត់បានសម្រេចដូចបញ្ជាថ្នាក់លើចឹង មានរឿងអីកើតឡើងចំពោះឃុំនឹង?

និន ៖ ទេ! មិនដែលឮ ។

ស៊ុយហៀង ៖ ដូចអត់មានអី?

និន ៖ បាទ! ឮថាម៉េច គ្រាន់តែថាប្រជុំនឹង ធ្វើឲ្យបានច្រើន បើវាមិនបានច្រើនធ្វើម៉េច ។

ស៊ុយហៀង ៖ ចុះលោកតាមានស្គាល់អ្នកផ្សេងទៀត ក្រៅពីអ្នកផ្សេងទៀតក្រៅពីអ្នកដែលស្លាប់ហើយនឹង អឺ!មានអ្នកនៅរស់ ហើយធ្លាប់ធ្វើ?

និន ៖ ភូមិ១ដែរ នៅរស់ ។

ស៊ុយហៀង ៖ ពីណាគេក៏បានភូមិឃុំ ឬមួយក៏មេកង មេស្រុក មេអីចឹង លោកតាដែលអាច? មានស្គាល់អ្នកណាគេ?

និន ៖ ទេ! ឥឡូវនឹងវាស្លាប់អស់ហើយ ម៉ាស្គាល់គ្នានឹង អាថ្មីក៏ស្លាប់ អាចាស់ក៏វាស្លាប់ ។ បើតាមខ្ញុំស្គាល់ៗច្រើនដែរ ប៉ុនឥឡូវវាស្លាប់អស់ទៅហើយ មកទៅសួរក៏មិនដឹងទៅសួរស្អី ។

ស៊ុយហៀង ៖ ស្លាប់អស់ខ្ញុំទៅសួរ?

និន ៖ ស្លាប់ទៅហើយ(សើច) ។ ម៉ាប៉ែកទៅត្បូងចេះវាអត់ស្គាល់ វាដាច់និយាយថាវាដាច់ក្រុម ដាច់ពួកចឹងទៅវាអត់ស្គាល់ ចឹងស្គាល់ម៉ាដួរនេះចេះទៅវាសូន្យហើយ ។

ជាតិ ៖ ចុះតាមុនឆ្នាំ៧៩ ភូមិនឹងមានគេជម្លៀសទៅស្រុកត្រាំកក់ទេ?

និន ៖ វារៀងត្រាំកក់ ទៅគ្រាន់ម៉ារត់ដូចថាយួនវាឡើងមកវៃគ្នានឹង អានឹងរត់មែន ទៅម៉ាថ្ងៃ២ថ្ងៃ វិលមកផ្ទះវិញមក ទៅដល់ត្រឹមតានីទៅអីនឹង ។

ជាតិ ៖ មិនមែនគេជម្លៀសឆ្នាំ៧៨ឲ្យទៅត្រាំកក់?

និន ៖ ៧៨ អានឹងរត់គេត្រូវឲ្យគៀងគរឲ្យឡើង ចេញពីភូមិទៅនឹងហើយ ព្រោះអានឹងទៅដល់នេះគេមិនឲ្យនៅទេ តែយើងនៅគេថាយើងនឹង ។

ជាតិ ៖ ឆ្នាំណា?

និន ៖ អានឹង៧៩នឹងដើម៧៩ ចុង៧៨នឹង ។ ខែយើងស្ទូងហើយ សន្ទូងបែកគុម្ពនឹង ខែមើលទាល់តែខែ៩ ខែ១០នឹង ។

ជាតិ ៖ ខែ១០ ៧៨?

និន ៖ អឺ! ខែ១០ ឥឡូវយើងខែ៧ ។

ជាតិ ៖ ខែអស្សុជ កត្តិកអី?

និន ៖ អឺ! ខែអស្សុជ កត្តិក ឡើងទៅស្រូវទុំនាយអាយហើយនឹង ។

ជាតិ ៖ ចឹងអ៊ំនៅត្រាំកក់ប៉ុន្មានខែដែរ?

និន ៖ ហ៉េ! មិនទៀត រត់ចុះឡើងៗដូចរត់ផ្លាស់កន្លែងដូចទន្សាយចឹង ។ ប៉ុនដល់ស្រូវគេទុំ អីគេឲ្យទៅច្រូតកាត់យកមកហូបទៅណាជំនាន់នឹង ។

ស៊ុយហៀង ៖ ចឹងលោកតាខ្ញុំអរគុណលោកតាច្រើនណ៎ា ។ ជម្រាបលា ។

និន ៖ បាទ! អញ្ជើញ ។

«ចប់»